ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ: ១០៤/១៧ អ.ជ.ជ

របាយការណ៍បូកសរុបសកម្មភាព
និងលទ្ធផលការងារបង្ការ-ទប់ស្កាត់ និងបង្ក្រាបអំពើជួញដូរមនុស្ស
និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែឧសភា និងទិសដៅខែមិថុនា ឆ្នាំ២០១៧

I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បាន និងកំពុងខិតខំយកចិត្តទុកដាក់ ជំរុញ ពង្រឹងកិច្ចសហប្រតិបត្តិការ សម្របសម្រួលជាមួយបណ្តាក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រេចបានលទ្ធផលជាច្រើន ដែលជាមោទនភាពសម្រាប់ការងារប្រយុទ្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទូទាំងប្រទេស ។ គ្រប់ក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានប្រឹងប្រែងយកអស់កម្លាំងកាយចិត្ត ដើម្បីសម្រេចបាននូវគោលដៅផែនការរបស់ខ្លួន។ តែយើងនូវមានការខ្វះខាតខ្លះដែលបណ្តាក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មួយចំនួនមិនទាន់ចែកដាច់ការងារ ដែលទាក់ទងនឹងខ្លឹមសារ ផ្តោតសំខាន់លើការងារប្រយុទ្ធប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។ ដូចនេះស្នើសុំឲ្យក្រសួង ស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិពិនិត្យឡើងវិញការផ្តល់របាយការណ៍របស់ខ្លួនមកអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ ហើយរបាយការណ៍ក្រសួង និងខេត្តមួយចំនួនត្រូវផ្ញើមកឲ្យបានទាន់ពេលកំណត់ តែក្រសួង និងខេត្តមួយចំនួនមានការយឺតយ៉ាវ ហើយបើយោងសេចក្តីសម្រេចលេខ០៩៤/១៤ ស.ស.រ ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន សម្រាប់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសេចក្តីសម្រេចលេខ០០១/១៤ ស.ស.រ ចុះថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ បូកសរុបរបាយការណ៍ដែលប្រមូលបានពីក្រុងស្រុកខណ្ឌ មន្ទីរ អង្គភាពពាក់ព័ន្ធ ប្រចាំខែ ត្រីមាស និងឆ្នាំ ស្តីពីសកម្មភាព លទ្ធផល ភាពប្រឈមជុំវិញការប្រឆាំងអំពើជួញដូរមនុស្ស និងទិសដៅ ដាក់ជូនអភិបាលរាជធានី ខេត្តដែលជាប្រធាន គ.រ.ប.ជ ឬ គ.ខ.ប.ជ ដើម្បីពិនិត្យ និងចុះហត្ថលេខារួចបញ្ជូនទៅអគ្គលេខាធិការដ្ឋានថ្នាក់ជាតិ មិនហួសពីថ្ងៃចុងក្រោយនៃខែនីមួយៗ។ របាយការណ៍ដែលអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបានគឺ ៖

- សម្រាប់បណ្តាក្រសួង ស្ថាប័ន ថ្នាក់ជាតិ មានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនងងឹតគ្រោះ) និងអគ្គស្នងការដ្ឋាននគរបាលជាតិ(ក្រុមការងារអនុវត្តន៍ច្បាប់)ចំនួន០២ ដែលបានផ្តល់របាយការណ៍ ។ដោយឡែកក្រសួងស្ថាប័នចំនួន៤ដែលជាយន្តការសម្របសម្រួលការងារដឹកនាំ និងអនុវត្ត ដើម្បីធានាឲ្យមានកិច្ចសហការរវាងក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀតមិនទាន់បានផ្ញើរបាយការណ៍។
- សម្រាប់បណ្តាស្ថាប័ន ថ្នាក់ក្រោមជាតិ មានលេខាធិការដ្ឋានរាជធានី/ខេត្តចំនួន២២ ដែលបានផ្តល់របាយការណ៍ដូចជា៖ រាជធានីភ្នំពេញ ,ខេត្តកោះកុង ព្រះសីហនុ កំពត តាកែវ កណ្តាល ព្រៃវែង ឧត្តរមានជ័យ ប៉ៃលិន បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ ព្រះវិហារ សៀមរាប កំពង់ធំ ក្រចេះ ស្ទឹងត្រែង

រតនគិរី កំពង់ ចាម ត្បូងឃ្មុំ ស្វាយរៀង និងខេត្តកំពង់ឆ្នាំង ។ ដោយឡែកលេខាធិការដ្ឋានខេត្តចំនួន៣ គឺខេត្ត កែប កំពង់ស្ពឺ និងខេត្តមណ្ឌលគិរី នៅមិនទាន់បានផ្ញើរបាយការណ៍ ។

II. ការអនុវត្តតាមផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

ក.ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

ដើម្បីសម្រេចបានតាមផែនការ យុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨) អគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយក្រសួង ស្ថាប័ន ជំនាញ ដៃគូពាក់ព័ន្ធជាតិ អន្តរជាតិ ក្នុងនោះមានស្ថានទូតផងដែរសម្រេចបានលិខិតបទដ្ឋានគតិយុត្តិមួយចំនួនដូចខាងក្រោម៖

- **គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានត្រៀមពិភាក្សាលើផែនការអនុវត្តកិច្ចព្រមព្រៀងកម្ពុជា-ឥណ្ឌា ស្តីពី«កិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស» ។
- **ក្រសួងកិច្ចការនារី** បាន និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី "ការគ្រប់គ្រងការពពោះជំនួស"
- **ក្រសួងយុត្តិធម៌** បាន និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"
- **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បាននិងកំពុងរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "សម្រាប់អនុវត្តលក្ខខ័ណ្ឌការងារកម្មករការងារផ្ទះ"
- **ក្រសួងអប់រំ យុវជន និងកីឬ** បាន និងកំពុងរៀបចំសេចក្តីព្រាងគោលនយោបាយ ស្តីពី "កិច្ចការការពារកុមារតាមសាលារៀន"

ខ.លើកកម្ពស់ការបង្ការទប់ស្កាត់

ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធ សហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយវេទិកាសាធារណៈ តាមប្រធានបទ "ភូមិឃុំមានសុវត្ថិភាព" បានចំនួន២.៤៥២លើក ថយចុះចំនួន**៤៧៧**លើក ស្មើនឹង១៦,២៨% (ធៀបនឹងខែមុនបានចំនួន២.**៩២៩**លើក) មានអ្នកចូលរួមសរុបចំនួន**៣២៦.៧**៤**៩**នាក់ ថយចុះចំនួន**១**៥.**៦**៨**១**នាក់ ស្មើនឹង**៤,**៥**៧**% (ធៀបនឹងខែមុនមានតែចំនួន**៣**៤**២.**៤**៣**០**នាក់) ក្នុងនោះស្ត្រីមានចំនួន**១**៧**៦.**២**៧**៧**នាក់ ។ (ឧបសម្ព័ន្ធទី១)

ខ.១-ការផ្សព្វផ្សាយតាមប្រព័ន្ធព័ត៌មាន

- ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគបាលខេត្តសៀមរាប បានធ្វើការផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធការជួញដូរមនុស្ស និងបទល្មើសផ្សេងៗ តាមប៉ុស្តិ៍វិទ្យុ បានចំនួន០**៤**លើក។

គ.ការគ្រប់គ្រងលំហូរពលករទេសន្តរប្រទេសន៍

គ.១-ការគ្រប់គ្រងបច្ចុប្បន្នភាពស្ថិតិចំណាកស្រុក

របាយការណ៍ពីអគ្គស្នងការដ្ឋាននគបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានចុះធ្វើស្ថិតិពលករចំណាកស្រុកទៅក្រៅប្រទេស៖

សរុបមានចំនួន**៣**២**៣.**៦**២**៨នាក់ (ស្រី**១**៣**៩.**៩**៤**៧នាក់) អនីតិជន ៨.**៧**២**៤នាក់ (ស្រី**៣.**៤**៨**១**នាក់) ក្នុងនោះចំណាកស្រុកស្របច្បាប់មានចំនួន**១**៨**៤.**៣**៣**៧នាក់(ស្រី**៨**៤.**២**៥**០នាក់) អនីតិជនចំនួន**១.**៣**០**១**នាក់ (ស្រី**៥**៧**៧**នាក់) និងចំណាកស្រុកមិនស្របច្បាប់មានចំនួន**១**៣**៩.**២**៩**១នាក់ (ស្រី**៥**៥.**៦**៩**៧**នាក់) អនីតិជនមានចំនួន**៧.**៤**២**៣**នាក់(ស្រី**២.**៩**០**៤**នាក់)។ ស្ថិតិនេះប្រៀបធៀបនឹងខែមុន(មេសា)កើនឡើងចំនួន**១**៩**០**នាក់ ស្មើនឹង**៧,**១**៤% ។

គ.២-ការគ្រប់គ្រងភ្នាក់ងារជ្រើសរើសឯកជន បញ្ជូនពលករទៅធ្វើការនៅបរទេស

ខេត្តពោធិ៍សាត់ មានក្រុមហ៊ុនឯកជននាំពលករខ្មែរទៅធ្វើការនៅប្រទេសថៃចំនួន០**៤**បានចំនួន០**៦**លើកមានក្រុមហ៊ុន៖

- CATM ASIA MANPOWER COOPERATION CO.LTD បានជ្រើសរើសពលករទៅធ្វើការនៅប្រទេសថៃ ដោយស្របច្បាប់ចំនួន០១ លើក មានពលករចំនួន១០នាក់(ស្រីចំនួន០៥នាក់)។
- B.S.R.O BEST MANPOWER CO.LTD បានជ្រើសរើសពលករទៅធ្វើការនៅប្រទេសថៃ ដោយស្របច្បាប់ចំនួន០១ លើក មានពលករចំនួន០៨នាក់(ស្រីចំនួន០៣នាក់)។
- SOK CHAMNOL CO.LTD បានជ្រើសរើសពលករទៅធ្វើការនៅប្រទេសថៃ ដោយស្របច្បាប់ចំនួន០២លើក មានពលករចំនួន១៦នាក់(ស្រីចំនួន០៨នាក់)។
- UNICORN MANPOWER CO.LTD បានជ្រើសរើសពលករទៅធ្វើការនៅប្រទេសថៃ ដោយស្របច្បាប់ចំនួន០២ លើក មានពលករចំនួន២៤នាក់(ស្រីចំនួន១០នាក់)។

គ.៣-ស្ថានភាពលំហូរជនទេសន្តរប្រវេសន៍

ខេត្តបន្ទាយមានជ័យ ក្រុមការងារទទួលជនទេសន្តរប្រវេសន៍បានរាយការណ៍ថា ថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញក្រោមរូបភាព «និរទេស» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន១៣០ដើងរថយន្ត មានពលករខ្មែរសរុបចំនួន៦១.៨១នាក់ (ថយចុះចំនួន៨.៧៦៩នាក់ បើប្រៀបធៀបនឹងខែមេសា) ស្រីចំនួន ២២.១៩នាក់ ក្នុងនោះកុមារចំនួន៥៤៩នាក់ (កុមារី២១៨នាក់)។ ការសម្គាសខ្លី បានរកឃើញថា៖

- បានចេញតាមច្រកអន្តរជាតិប៉ោយប៉ែត ២.៥២៨ នាក់ តាមច្រករបៀង ៣.៦៥៣ នាក់
- ចេញដោយខ្លួនឯង ២.៨២៥ នាក់ តាមរយៈគេនាំ ៣.៣៥៦ នាក់

បានជាប់ពន្ធនាគារ លើសពី ១ខែ មានចំនួន ១៥៥ នាក់ ។ ពួកគាត់មានខ្លះជាប់ឃុំរយៈពេល១៥ឆ្នាំ, ១២ឆ្នាំ ០៨ឆ្នាំ ដោយមូលហេតុខ្លះស៊ីឈ្នួលកាន់គ្រឿងញៀន ខ្លះចូលទៅលួចកាប់ឈើគ្រញូង ខ្លះស៊ីឈ្នួលដឹករបស់ក្លែងក្លាយ ខ្លះកាន់ប៉ាស្ប័ររូបអ្នកផ្សេង ដែលមេខ្យល់ឲ្យកាន់ អ្នកគ្មានប័ណ្ណស្នាក់នៅត្រូវជាប់រយៈពេល២ខែ។

ក្រុមការងារបានសម្គាសពលករចំនួន២៩៤នាក់ (ស្រី២៦៣នាក់) មិនបានរកឃើញអត្តសញ្ញាណជនសង្ស័យនាំមនុស្សឆ្លងដែនទេ។ ការសម្គាសកុមារចំនួន៤៨នាក់ (កុមារី ១៩នាក់) បានរកឃើញកុមារ២៩នាក់ ទៅតាមឪពុកម្តាយ និងកុមារ១៩នាក់ ទៅតាមបងប្អូន ។

គ.៤-វិធានការគ្រប់គ្រងជំនាញ

គ.៤.១-ការងារបង្ការទប់ស្កាត់តាមវិធានការជំនាញរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ

- **ស្នងការដ្ឋាននគរបាលខេត្តសៀមរាប** បានចុះធ្វើស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តអំពើសញ្ជារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារ ក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន៣៨៨គោលដៅ មានមនុស្សចំនួន២.២៣៥នាក់ (ស្រី ១.៩៤១នាក់)។
- **ស្នងការដ្ឋាននគរបាលខេត្តកំពង់ចាម** បានចុះធ្វើស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តអំពើសញ្ជារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន១៩គោលដៅ មានមនុស្សចំនួន៧២នាក់ (ស្រី ៤៨នាក់)។
- ស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង បានចុះធ្វើស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ ការប្រព្រឹត្តអំពើសញ្ជារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ស្ត្រីបម្រើការងារក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន១៣លើកមានមនុស្សចំនួន១០៨នាក់ (ស្រី៦២នាក់)។
- **ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ** ៖ បានធ្វើការបង្ក្រាបទប់ស្កាត់ពលករខ្មែរធ្វើចំណាកស្រុកខុសច្បាប់

ទៅធ្វើការនៅប្រទេសថៃ បានចំនួន១១លើក មានមនុស្សចំនួន**៤៧៧**នាក់(ស្រី**១៨១**នាក់) និង

- កម្លាំងនគរបាលប៉ុស្តិ៍គោករមៀតប៉ុស្តិ៍អូរ៣ជាន់ និងវរៈនគរបាលការពារព្រំដែនគោកលេខ(**៩១១** និង**៨០៧**) បានធ្វើការបង្ក្រាបទប់ស្កាត់ពលករខ្មែរធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ បានចំនួន **១៣**លើក មានមនុស្សចំនួន**៥៨២**នាក់(ស្រី**២០២**នាក់ អនីតិជន**៤៩**នាក់) ក្រោយពីពេលធ្វើការសាកសួរ អប់រំ ណែនាំ និងបានធ្វើកិច្ចសន្យា ហើយបានឲ្យពួកគាត់វិលទៅកលំនៅដ្ឋានវិញ ។

- **ស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង** វរៈនគរបាលការពារព្រំដែនគោកលេខ(**៨១៧** ,**៨១៩** ,**៨២៣** និង**៣១០**) បានធ្វើការបង្ក្រាបទប់ស្កាត់ពលករខ្មែរធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ បានចំនួន **០៤**លើក មានមនុស្សចំនួន**៣៥**នាក់(ស្រី**០៩**នាក់) ក្រោយពីពេលធ្វើការសាកសួរ អប់រំ ណែនាំ និងបានធ្វើកិច្ចសន្យា ហើយបានឲ្យពួកគាត់វិលទៅកលំនៅស្ថានវិញ ។

- **ស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ** អង្គការម្លប់តាប៉ាង បានចុះចលនាដាក់បណ្តាញភ្នាក់ងារដើម្បីសុវត្ថិភាពកុមារ លើក្រុមម៉ូតូឌុប ក្រុមម៉ូតូកង់បី បណ្តាញសហគមន៍ បណ្តាញអ្នកលក់តាមឆ្នេរសមុទ្រ បុគ្គលិកតាមផ្ទះសំណាក់ និងសណ្ឋាគារ សរុបចំនួន**៦២៩**នាក់ ។

គ.៤.២-ការបង្ការទប់ស្កាត់តាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស

របាយការណ៍ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ជាសេនាធិការ បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេស ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ចំនួន**១២៤**គូ និងបានទំនាក់ទំនងតាមរយៈទូរស័ព្ទផ្ទាល់ទៅនារីខ្មែរចំនួន**០៤**នាក់ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេស ចម្លើយការរស់នៅជាមួយគ្រួសារមានសេចក្តីសុខសប្បាយជាធម្មតា។

ឃ.ការពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

ឃ.១ ការងារអនុវត្តច្បាប់

ឃ.១.១-ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

ក្រុមការងារអនុវត្តន៍ច្បាប់(អគ្គស្នងការដ្ឋាននគរបាលជាតិ) បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទបានចំនួន**០៥**ករណី/**០៧**ករណី(បើប្រៀបធៀបខែមុនថយចុះ**០២**ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងបានចំនួន**០៨**នាក់(ស្រី**០៣**នាក់) សង្គ្រោះជនរងគ្រោះបានចំនួន**១០**នាក់ ក្នុងនោះអាយុក្រោម**១៥**ឆ្នាំចំនួន**០៦**នាក់ អាយុពី**១៥-១៧**ឆ្នាំចំនួន**០១**នាក់ និងអាយុ**១៨**ឆ្នាំឡើងបានចំនួន**០៣**នាក់ (បានប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន**០៤**នាក់ និងគ្រួសារចំនួន**០៦**នាក់) ។

- **ការបង្ក្រាបអំពើជួញដូរមនុស្ស**

សរុបបាន**០៣**ករណី/**០២**ករណី ជនសង្ស័យចំនួន**០៦**នាក់(ស្រី**០៣**នាក់) ជនរងគ្រោះបានចំនួន**០៨**នាក់ ក្នុងនោះអាយុក្រោម**១៥**ឆ្នាំចំនួន**០៤**នាក់ អាយុពី**១៥-១៧**ឆ្នាំចំនួន**០១**នាក់ និងអាយុ**១៨**ឆ្នាំឡើងមានចំនួន**០៣**នាក់ (ហើយបានប្រគល់ឲ្យមន្ទីរសង្គមកិច្ចចំនួន**០៤**នាក់ និងគ្រួសារចំនួន**០៤**នាក់) ។

- ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន	**០២**ករណី ជនសង្ស័យ **០៤**នាក់ (សញ្ជាតិចិនចំនួន**០២**នាក់)
- ការទិញពេស្យាចារកុមារ	**០១**ករណី ជនសង្ស័យ **០២**នាក់ (សញ្ជាតិអង់គ្លេសចំនួន**០១**នាក់)

- **ការបង្ក្រាបអំពើធ្វើអាជីវកម្មផ្លូវភេទ**

សរុប**០២**ករណី/**០៥**ករណី ជនសង្ស័យចំនួន**០២**នាក់ ក្នុងនោះជនរងគ្រោះចំនួន**០២**នាក់ អាយុក្រោម**១៥**ឆ្នាំ

ចំនួន០២នាក់ (ហើយបានប្រគល់ឲ្យគ្រួសារវិញ) ។

-អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ០២ករណី ជនសង្ស័យ ០២នាក់

យ.២ កិច្ចការយុត្តិធម៌

យ.២.១ លទ្ធផលចំណាត់ការផ្តន្ទាទោស(ពុំមានទិន្នន័យ)

យ.២.២-ការរៀបចំបទដ្ឋានគតិយុត្ត និងច្បាប់

- សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" រវាងព្រះរាជាណាចក្រកម្ពុជា និង សាធារណរដ្ឋប្រជាមានិតឡាវ និងរដ្ឋាភិបាលបារាំង និងរដ្ឋាភិបាលរុស្សី ។
- សេចក្តីព្រាងកិច្ចព្រមព្រៀង ស្តីពី "បញ្ជូនទណ្ឌិត" រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលអង់គ្លេស និង រដ្ឋាភិបាលប៉េរូ និងសាធារណរដ្ឋប្រជាមានិតឡាវ និង រដ្ឋាភិបាលរុស្សី ។

១.កិច្ចការពារជនរងគ្រោះ ព្រមទាំងសេវាគាំទ្រ

ង.១- ស្ថិតិពលករដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេស តាមច្រកព្រំដែន

របាយការណ៍ទទួលពីក្រុមការងារអនុវត្តន៍ច្បាប់(អគ្គស្នងការនគរបាលជាតិ) ពលករទេសន្តរប្រវេសន៍ ការងារបញ្ជូនត្រឡប់មកពីច្រកព្រំដែនកម្ពុជា-ថៃ និងច្រកព្រំដែនកម្ពុជា-វៀតណាម សរុបចំនួន ៥.៩៣១នាក់ (ស្រី២.១៤២នាក់)អនីតិជនចំនួន៦៦២នាក់ (ស្រី១៦២នាក់) ដែលមកតាម ៖

- ច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ៥.៣៦៧នាក់ (ស្រី១.៩២៩នាក់ ,អនីតិជន៦២០នាក់ (ស្រី១៤៥នាក់)
- ច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបងចំនួន១៩៤នាក់ (ស្រី៧៩នាក់ ,កុមារ០៤នាក់)
- ច្រកភ្នំដី ស្រុកសំពៅលូន ខេត្តបាត់ដំបងចំនួន៣៧០នាក់(ស្រី១៣៤នាក់,កុមារ៣៨នាក់,កុមារី១៧នាក់)

ក្នុងនោះពលរដ្ឋខ្មែរចំនួន១៥៥នាក់ ត្រូវអាជ្ញាធរថៃយាត់ខ្លួនលើសពីរយៈពេល១ខែមុន និងបញ្ជូនមកកម្ពុជាវិញ។ ហើយបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅឋានវិញ ។

ង.២-ការសម្អាតពលករចាប់បញ្ជូនត្រឡប់តាមច្រកព្រំដែន(ផ្លូវគោក និងផ្លូវអាកាស)

- ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានសម្អាតដើម្បីកំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលប្រទេសថៃបញ្ជូនមក បានចំនួន១៨នាក់(ស្ត្រី០២នាក់) ក្នុងនោះមានកុមារចំនួន១២នាក់(កុមារី០៤នាក់)មកជាមួយគ្រួសារ ។

  បញ្ជាក់ៈ--ចំនួន១១នាក់(ស្រី០១នាក់ កមារ០៩នាក់(កុមារី០៤នាក់) ងាយរងគ្រោះដោយអំពើជួញដូរមនុស្ស

  –ចំនួន០២នាក់(ស្រី០១នាក់) រងគ្រោះដោយការកេងប្រវ័ញ្ចកម្លាំងពលកម្ម។

  –ចំនួន០៥នាក់(កុមារ០៣នាក់) រងគ្រោះដោយការជួញដូរកម្លាំងពលកម្ម។

- ក្រុមការងារអនុវត្តន៍ច្បាប់(អគ្គស្នងការដ្ឋាននគរបាលជាតិ)បានស្រង់ឈ្មោះជនរងគ្រោះដែលបញ្ជូនមកពីក្រៅប្រទេស មានចំនួន០៩នាក់ ទៅតាមរយៈមេខ្យល់ ក្នុងនោះ៖
  - មកពីប្រទេសម៉ាឡេស៊ី ចំនួន០៧នាក់
  - មកពីប្រទេសចិន ចំនួន០២នាក់
- ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានស្រង់ឈ្មោះជនរងគ្រោះដែលបញ្ជូនមកពីក្រៅប្រទេស តាមរយៈក្រសួងការបរទេស មានចំនួន១៦នាក់(ស្រី) មកពីប្រទេសម៉ាឡេស៊ី ជំនួយឧបត្ថម្ភដោយអង្គការ MOI ។

ង.៣ ការទទួលជនសង្ស័យរងគ្រោះតាមរយៈស្ថានទូត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាៈ
  - ○ ក្រសួងការបរទេសបានទទួកពលការនីខ្មែរធ្វើមាតុភូមិនិវត្តន៍ ពីប្រទេសម៉ាឡេស៊ីចំនួន១៤នាក់ (ស្រី០៨នាក់) ករណីជួញដូរកម្លាំងពលកម្ម ។
  - ○ មន្ទីរសង្គមកិច្ច ស.អ.យ រាជធានីភ្នំពេញ បានទទួលនារីរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន ០៣នាក់(ករណីជួញដូរឆ្លងដែនទៅប្រទេសចិន) ។

ង.៤ ការគ្រប់គ្រងជនងាយរងគ្រោះនៅក្នុងមណ្ឌល

មន្ទីររាជធានីភ្នំពេញសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាៈ

- ○ បានទទួលជនអនាថាមិនស្ម័គ្រចិត្តសរុបចំនួន៨២នាក់(ស្រី១៦នាក់ ,កុមារាចំនួន០៨នាក់ ,កុមារី០១នាក់ ដោយបានបញ្ជូនជនរងគ្រោះទាំងនេះ ទៅមណ្ឌលសំចតនៅមន្ទីរ ស.អ.យ រាជធានីភ្នំពេញទាំងចំនួន ៨២នាក់ ដើម្បីអប់រំ និងបណ្តុះបណ្តាលរយៈពេលខ្លី មុននឹងសមាហរណកម្មទៅសហគមន៍វិញ ។
- ○ បានទទួលនារីរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន០៣នាក់ ទៅមណ្ឌលសំចតនៅមន្ទីរ ស.អ.យ រាជធានីភ្នំពេញ ដើម្បីអប់រំ និងបណ្តុះបណ្តាលរយៈពេលខ្លី មុននឹងសមាហរណកម្មទៅសហគមន៍វិញ ។

ង.៥ សេវាជួយជនរងគ្រោះដែលបានផ្តល់

- **មណ្ឌលសំចត ខេត្តបន្ទាយមានជ័យ** បានបញ្ជូនជនរងគ្រោះ១៨នាក់ ទៅអង្គការកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិចំនួន០៧នាក់ ក្នុងនោះមានស្ត្រី០១នាក់,កុមារី០៣នាក់,កុមារា០២នាក់។ អង្គការដំណាក់ទឹកកុមារី០៦នាក់ ក្នុងនោះមានស្ត្រី០១នាក់,កុមារី០១នាក់,កុមារា០៣នាក់។ និងអង្គការសាម៉ារីតាន់ភ៉ីសចំនួន០៥នាក់ ក្នុងនោះមានបុរស០២,កុមារា០៣នាក់។ ដើម្បីបានទទួលសេវាស្នាក់នៅសុវត្ថិភាពអប់រំក្នុង និងក្រៅប្រព័ន្ធបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងសេវាផ្សេងៗ ។

ង.៦ សមាហរណកម្មជនរងគ្រោះ

- **មន្ទីរសង្គមកិច្ច ស.អ.យ រាជធានីភ្នំពេញ** បានសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ធ្វើសមាហរណកម្មជនរងគ្រោះដោយការជួញដូរមនុស្សឆ្លងដែនខុសច្បាប់ពីប្រទេសចិនចំនួន ០៣នាក់ ទៅអង្គការមេត្រីអន្តរជាតិដើម្បីអាស៊ី AIM ចំនួន០១នាក់ និងអង្គការ HAGAR ចំនួន០២នាក់ ។
- **មន្ទីរសង្គមកិច្ច ស.អ.យ ខេត្តបាត់ដំបង** បានចុះពិនិត្យ និងសហការជាមួយអង្គការកុមារីក KMR ធ្វើសមាហរណកម្ម នារីរងគ្រោះដោយអំពើជួញដូរផ្លូវភេទចំនួន០១នាក់ ទៅរស់ជាមួយគ្រួសារ ក្នុងសហគមន៍ នៅក្នុងភូមិព្រៃកឆ្ពោ ស្រុកឯកភ្នំ ។
- **មន្ទីរសង្គមកិច្ច ស.អ.យ ខេត្តក្រចេះ** បានធ្វើសមាហរណកម្មជនរងគ្រោះដោយការជួញដូរមនុស្ស ឆ្លងដែនខុសច្បាប់ពីប្រទេសម៉ាឡេស៊ី ចំនួន០៦នាក់ ត្រូវបានបញ្ជូនឲ្យទៅរស់នៅក្នុងសហគមន៍វិញ ។
- **មន្ទីរសង្គមកិច្ច ស.អ.យ ខេត្តកំពត** បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន១១នាក់ មកពីអង្គការ ពន្លឺ ព្រះអាទិត្យ អង្គការទស្សនៈពិភពលោក អង្គការមេត្រីភាពដើម្បីក្តីសង្ឃឹមអន្តរជាតិ អង្គការ ជួយសង្គ្រោះ ជោគវាសនាកល្យាណមិត្ត មណ្ឌលHOCកោះកុងឡូធ៍សវ៉ីលអង្គការសួនៃក្តី សង្ឃឹមកម្ពុជា និងអង្គការហ្គ្រា រាជធានីភ្នំពេញ ។ Pitha

III. ការលើកកម្ពស់សមត្ថភាព

ក.ក្នុងប្រទេស

ក.១-បណ្តុះបណ្តាល

- ខេត្តបន្ទាយមានជ័យ ៖ ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយអង្គការ IOM បានរៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីយន្តការបណ្តឹងសម្រាប់ពលករទេសន្តរប្រវេសន៍បានចំនួន២ថ្ងៃ ។
- ខេត្តព្រះវិហារ ៖ ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការទស្សនៈពិភពលោក បើកវគ្គបណ្តុះបណ្តាលដល់គ្រូបង្គាលក្នុងសហគមន៍ នៅស្រុកត្បែងមានជ័យ ស្តីពីការកំណត់បទល្មើស និងការបញ្ជូនកុមារងគ្រោះ បានចំនួន០២វគ្គ មានសិក្ខាកាមចំនួន៣៦នាក់ (ស្រី១៤នាក់)។
- ខេត្តកោះកុង ៖ ស្នងការដ្ឋាននគរបាលខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការងារបង្ការទប់ស្កាត់ អំពើជួញដូរមនុស្ស ដល់មន្ត្រីនគរបាលថ្មីដែលទើបនឹងជ្រើសរើសនៅក្នុងខេត្ត បានចំនួន០១វគ្គ មានសិក្ខាកាមចំនួន ៥៦នាក់ (ស្រី១១នាក់)។
- ខេត្តព្រះសីហនុ ៖ ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយ មន្ទីរទេសចរណ៍ខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីបដិសណ្ឋារកិច្ច និងសេវាកម្មមណ្ឌលកម្សាន្តទេសចរណ៍ មនុស្សពេញវ័យ បានចំនួន០១វគ្គ មានសិក្ខាកាមចំនួន៤៩នាក់ (ស្រី១៥នាក់)។

ក.៣-សម្របសម្រួលកិច្ចប្រជុំ

ការងារដឹកនាំសម្របសម្រួលសរុបបានចំនួន៣៩លើក៖ ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន១៣លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន២៦លើក ។ (**ឧបសម្ព័ន្ធទី២**)

ខ.ក្រៅប្រទេស

ខ.១ សកម្មភាពចូលរួមប្រជុំ

- លោកឧត្តមសេនីយ៍ត្រី ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ **នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានចូលរួមកិច្ចប្រជុំឧត្តមមន្ត្រីអាស៊ានលើកទី១៧ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន (នៅក្រុងវៀងច័ន្ទប្រទេសឡាវ)។
- **ខេត្តបន្ទាយមានជ័យ** បានចូលរួមប្រជុំជាមួយភាគីថៃ ស្តីពីនីតិវិធីក្នុងការបញ្ជូនត្រឡប់ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងភាពប្រឈម ក្នុងនោះមានសមាសភាពចូលរួមខាងភាគីកម្ពុជាចំនួន២០នាក់ ខាងភាគីថៃចំនួន៣៥នាក់ (នៅប្រទេសថៃ)។
- **ខេត្តរតនគិរី** បានចូលរួមប្រជុំថ្នាក់ប៉ុស្តិ៍នៃ(វ:ការពារព្រំដែនលេខ៦២៣ និង២០៣)ជាមួយភាគីឡាវ និងភាគីវៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការ រក្សាសន្តិសុខ សណ្តាប់ធ្នាប់តាមបណ្តោយព្រំដែន និងបញ្ហាប្រជាជនឆ្លងដែនខុសច្បាប់ បានចំនួន២៣លើក ។

ខ.២-សន្និសីទ

- លោកជំទាវរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ **និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស** បានអញ្ជើញចូលរួមសន្និសីទអាស៊ាន ស្តីពីសារៈសំខាន់នៃបញ្ហា ផ្ទៃកច្បាប់ក្នុងតំបន់នៅប្រទេសសិង្ហបុរី ។

ខ.៣-សិក្ខាសាលា

- លោកឧត្តមសេនីយ៍ត្រី ប្រធានក្រុមចំនួយកិច្ចការអន្តរជាតិ **នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិប្រយុទ្ធ**

ប្រឆាំងអំពើជួញដូរមនុស្ស បានអញ្ជើញចូលរួមសិក្ខាសាលាអាស៊ានសម្រាប់អ្នកប្រតិបត្តិផ្នាល់ ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យច្បាប់នៅក្នុងរឿងក្តីជួញដូរមនុស្ស(នៅទីក្រុងបាងកកប្រទេសថៃ)។

គ.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជោគជ័យគួរកត់សម្គាល់ ៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី **រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធានគ.ជ.ប.ជ** គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងសមាសភាពទាំងមូលដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ស្កាត់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បញ្ជាប៉ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារនេះ ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិការតាមក្រសួង ស្ថាប័ន អង្គភាពរៀងគរចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

ឃ.ចំណុចខ្វះខាត

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ថ្វីត្បិតតែយើងបានបង្កើតក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស ។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណាដែលទាក់ទងនឹងអំពើជួញដូរមនុស្ស។ ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃ សកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាពបានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបាន

សរសេរអស់នូវសកម្មភាព និងទិន្នន័យដែលក្រសួង ស្ថាប័ន ឬអង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនទទួលបានលទ្ធផលល្អតាមរបាយការណ៍នោះដែរ។

ខ.សំណូមពរ

- ➢ គ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមដំនាញរៀងៗខ្លួន។
- ➢ វគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ➢ ក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិយកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធានគ.ជ.ប.ជ បានសម្រេច។

IV. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ ពីរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការ សហប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះខាតក្នុង កិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើនពីអំពើជួញដូរមនុស្សមានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ ចេញបញ្ជាតពីពួកឧក្រិដ្ឋជនកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃ ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាជាមិនខាន។

V. ទិសដៅខែមិថុនា ឆ្នាំ២០១៧

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួម បែងចែកការកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព ។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់រូបភាព ជាអាទិ៍ ៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ជួញដូរ និងដកហូតសរីរាង្គ ជួញដូរ និងរត់ពន្ធទារក និងកុមារ ឆ្លងដែន ការពពោះជំនួស ការជួញដូរពលកម្មក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។ ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា ។

៣. រៀបចំសកម្មភាពសម្រាប់ការអនុវត្តផែនការសកម្មភាពជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ពាក់កណ្តាល អាណត្តិទី២ ៖ ២០១៧-២០១៨) ។

៤. ត្រៀមចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌា និងជាមួយប្រទេសពាក់ព័ន្ធដទៃទៀត។

៥. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌ ។

៦. គាំទ្រ និងពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត ។

៧. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកលអំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រីទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ ។

៨. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាម បណ្តាក្រសួងស្ថាប័នអង្គការដៃគូក្នុងស្រុកនិងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត ។

៩. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី **នៃព្រះរាជាណាចក្រកម្ពុជា** បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥ ។

១០. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១១. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ) ។

១២. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ ។

១៣. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ។

Pitha

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ១០ ឆ្នាំ២០១៧

អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

ជ.ប.ជ

ជ.ប.ជ

ចម្លងជូន៖

-ឧកាលីយសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ "ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១

ការងារផ្សព្វផ្សាយ

ល.រ	អង្គភាព	សកម្មភាព	អង្គភាព-ស្ថាប័នពាក់ព័ន្ធ	លើក	ចំនួនមនុស្ស	ស្រី
1	ព្រះវិហារ	ផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងការទប់ស្កាត់អំពើជួញដូរមនុស្ស ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ និងលោកគ្រូ អ្នកគ្រូសិស្សានុសិស្ស និងប្រជាពលរដ្ឋនៅតាមភូមិ/ឃុំ/ស្រុក ។	លេខាធិការដ្ឋានខេត្ត	4 លើក	814 នាក់	454 នាក់
2	បាត់ដំបង	បានធ្វើវេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ ប្រជាពលរដ្ឋ នៅក្រុង/ស្រុកទូទាំងខេត្ត ។	ក្រុមការងារគណៈបញ្ជាការឯកភាព ក្រុង/ស្រុក និងអគ្គ ស្នងការនគរបាលខេត្ត	488 លើក	77,615 នាក់	41,193 នាក់
3	កណ្តាល	ផ្សព្វផ្សាយច្បាប់ស្តី អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិសេសលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ ។	ក្រុមការងារថ្នាក់ស្រុក	31 លើក	953 នាក់	637 នាក់
		ផ្សព្វផ្សាយ ស្តីអំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ពិសេសលើស្ត្រី និងកុមារ ដល់ប្រជាពលរដ្ឋនៅឃុំក្រាំងម្ទាក់ ស្រុកអង្គស្នួល ។	ក្រុមការងារថ្នាក់ស្រុក និងអង្គការមូលនិធិសិទ្ធកុមារ	1 លើក	120 នាក់	174 នាក់
		ផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ ស្តីពីទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព០៩ចំណុច ដល់ប្រជាពលរដ្ឋនៅភូមិឃុំ ក្រុង ស្រុកទូទាំងខេត្ត ។	ក្រុមការងារថ្នាក់ក្រុង/ស្រុក	129 លើក	21,591 នាក់	12,622 នាក់
4	កំពត	ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវ ភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅភូមិ ឃុំ សង្កាត់ ក្រុង/ស្រុក ។	ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ថ្នាក់ខេត្ត/ក្រុង/ស្រុក និងមន្ទីរ អង្គភាពពាក់ព័ន្ធ	9 លើក	827 នាក់	343 នាក់
		ផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅនៅភូមិ ឃុំ សង្កាត់ ក្រុង/ស្រុក ។		2 លើក	199 នាក់	106 នាក់
		ផ្សព្វផ្សាយ ស្តីពីការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅនៅភូមិ ឃុំ សង្កាត់ ក្រុង/ស្រុក ។	ក្រុមការងារអនុត្តន៍ច្បាប់ និងអង្គការអាដហុក	2 លើក	46 នាក់	22 នាក់

5	តាកែវ	ផ្សព្វផ្សាយច្បាប់ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅភូមិ/ឃុំ/ក្រុង/ស្រុក ។	ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត ស្នងការដ្ឋាននគរបាលខេត្ត	63 លើក	6,699 នាក់	3,024 នាក់
		ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅភូមិ/ឃុំ/ក្រុង/ស្រុក ។		22 លើក	1,180 នាក់	477 នាក់
6	កំពង់ធំ	ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងផលប៉ះពាលនៃការធ្វើចំណាកស្រុក ដល់ប្រជាពលរដ្ឋនៅតាម ភូមិ ឃុំ ស្រុក ។	ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ស្រុក	4	105 នាក់	80 នាក់
7	សៀមរាប	បានផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីបែបបទ និងនិតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស នៅក្នុងស្រុកក្រឡាញ់ ។	លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត	1 លើក	88 នាក់	81 នាក់
		ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅឃុំគោកធ្លកក្រោម ស្រុកជីក្រែង។	លេខាធិការដ្ឋាន គ.ខ.ប.ជ និងអង្គការការីតាស់	1 លើក	45 នាក់	30 នាក់
8	ពោធិ៍សាត់	ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស នៅតាមឃុំ សង្កាត់ ទូទាំងខេត្ត ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ,ស្រុកក្រគរ និងស្រុក ភ្នំក្រវ៉ាញ ។	ស្នងការដ្ឋាននគរបាលខេត្ត	20 លើក	2,173 នាក់	1,089 នាក់
		ផ្សព្វផ្សាយតាមរយៈភូមិ/ឃុំ មានសុវត្ថិភាព ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅក្រុងពោធិ៍សាត់ ,ស្រុកបាកាន ,ស្រុកក្រគរ ស្រុកកណ្តៀង ,ស្រុកបាកាន ,ស្រុកភ្នំក្រវ៉ាញ និងស្រុកវាលវែង ។	ក្រុមការងារថ្នាក់ស្រុក	244 លើក	77,156 នាក់	42,413 នាក់
9	កំពង់ឆ្នាំ	ផ្សព្វផ្សាយលក្ខណៈសម្បត្តិ ៩យ៉ាង អំពីគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ។	លេខាធិការដ្ឋានខេត្ត/ក្រុង/ស្រុក	464 លើក	54,422 នាក់	29,079 នាក់
		ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។		493 លើក	57,073 នាក់	30,730 នាក់
10	កំពង់ចាម	ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់ម្ចាស់អាជីវកម្ម និងអ្នកបម្រើការងារនៅក្នុងសណ្ឋាគារ ។	ស្នងការដ្ឋាននគរបាលខេត្ត	1 លើក	72 នាក់	58 នាក់

11	ត្បូងឃ្មុំ	វេទិកាផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់សិស្សានុសិស្ស ប្រជាពលរដ្ឋ ទូទាំងក្រុង/ស្រុក ។	មន្ទីរអប់រំយុវជន និងកីឬា និងលេខាធិការដ្ឋានខេត្ត/ក្រុង/ស្រុក	13 លើក	453 នាក់	354 នាក់
12	រតនៈគិរី	ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។	ស្នងការដ្ឋាននគរបាលខេត្ត	3 លើក	191 នាក់	73 នាក់
13	ឧត្តរមានជ័យ	វេទិកាផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់សិស្សានុសិស្ស ប្រជាពលរដ្ឋ ទូទាំងក្រុង/ស្រុក ។	លេខាធិការដ្ឋានខេត្ត/ក្រុង/ស្រុក	31 លើក	1,424 នាក់	652 នាក់
		វេទិកាផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅស្រុកអន្លង់វែង ។		1 លើក	110 នាក់	85 នាក់
14	ក្រចេះ	ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ នៅភូមិស្រែនន ស្រុកចិត្របូរី និងភូមិស្រែ ស្ពៅ ស្រុកសំបូរ ។	លេខាធិការដ្ឋានខេត្ត និង មន្ទីរកិច្ចការនារី	2 លើក	89 នាក់	67 នាក់
15	ព្រះសីហនុ	ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋ នៅស្រុកកំពង់សីឡា និងស្រុកព្រៃនុប។	លេខាធិការដ្ឋានខេត្ត ស្រុក មន្ទីរកិច្ចការនារី និងស្នងការដ្ឋាននគរបាលខេត្ត	3 លើក	1,217 នាក់	912 នាក់
16	តាកែវ	ផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការទប់ស្កាត់ការជួញដូរកម្លាំងពលកម្មកុមារ ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក ។	លេខាធិការដ្ឋានខេត្ត ថ្នាក់ក្រុង ស្រុក និងស្នងការដ្ឋាននគរបាលខេត្ត	63 លើក	6,699 នាក់	3,024 នាក់
		ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ:ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការទប់ស្កាត់ការជួញដូរកម្លាំងពលកម្មកុមារ ដោយបញ្ជ្រាបក្នុងគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាពដល់ប្រជាពលរដ្ឋនៅតាមភូមិ/ឃុំ សង្កាត់ ក្រុង/ស្រុក ។		22 លើក	1,180 នាក់	477 នាក់
17	ស្វាយរៀង	ផ្សព្វផ្សាយ តាមរយៈវេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ នៅក្រុងស្វាយរៀង ក្រុងបាវិត និងស្រុកចន្ទ្រា ។	លេខាធិការដ្ឋានថ្នាក់ក្រុង ស្រុក	335 លើក	14,208 នាក់	8,021 នាក់

សកម្មភាពសរុបៈចំនួន: 2,452 លើក

មនុស្សសរុបចំនួន: 326,749 នាក់

ស្រីសរុបចំនួន : 176,277 នាក់

ឧបសម្ព័ន្ធទី២

តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៣៩លើក)

ស្ថាប័ន សម្របសម្រួល	សកម្មភាព
គណៈកម្មាធិការជាតិ គ.ជ.ប.ជ	- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួងផ្សព្វផ្សាយបង្ហាញលទ្ធផល ស្តីពីការវាយតម្លៃ៣ក់កណ្តាលអាណត្តិ នៃផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រយៈពេល ០៥ឆ្នាំ ២០១៤-២០១៨ នៅទីស្តីការក្រសួងមហាផ្ទៃ ។ - បានអញ្ជើញចូលរួមកិច្ចប្រជុំស្តាប់របាយការណ៍ ស្តីពីការផ្តល់ឯកសារស្របច្បាប់ជូនពលករកម្ពុជាធ្វើការនៅប្រទេសថៃ នៅទីស្តីការក្រសួងមហាផ្ទៃ ។ - បានដឹកនាំប្រជុំត្រៀមរៀបចំសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីការលើកកម្ពស់ការទទួលបានសិទ្ធិ និងកិច្ចគាំពារកុមារបន្លាស់ទី នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។ - បានអញ្ជើញចុះតាមដាន និងត្រួតពិនិត្យគោលនយោបាយភូមិឃុំមានសុវត្ថិភាព នៅខេត្តកំពង់ឆ្នាំង ។ - បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីការរៀបចំនីតិវិធីអនុវត្តសេចក្តីជូនដំណឹងលេខ ២៥៣សជណ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីសុំគោលការណ៍ដោះស្រាយករណីទារក ដែលកើតដោយការជួលស្ត្រីខ្មែរឲ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។ - បានអញ្ជើញជាគណៈអធិបតីក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីការលើកកម្ពស់ការទទួលបានសិទ្ធិ និងកិច្ចគាំពារកុមារបន្លាស់ទី ដែលសហការរៀបចំ និងសម្របសម្រួលដោយ Cambodia ACTs, Terre des Homes, NGOCRC, PLAN, OAK Foundation, ក្រុមប្រឹក្សាជាតិដើម្បីកុមារ និងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅភ្លោជនីយ៍ដ្ឋានទន្លេបាសាក់២ ។ - បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ស្តីពីការរៀបចំនីតិវិធីអនុវត្តសេចក្តីជូនដំណឹងលេខ ២៥៣សជណ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីសុំគោលការណ៍ដោះស្រាយករណីទារកដែលកើតដោយការជួលស្ត្រីខ្មែរឲ្យពពោះជំនួស ដើម្បីយកទារកចេញទៅចិញ្ចឹមនៅក្រៅប្រទេស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន ។ - បានអញ្ជើញចូលរួមពិធីបើកសិក្ខាសាលា ស្តីពីការចែករំលែកចំណេះ ដឹងអំពីការអនុវត្តជោគជ័យនៅក្នុងផ្នែកអធិការកិច្ចការងារ និងលុបបំបាត់ពលកម្មកុមារនៃវិស័យសេដ្ឋ កិច្ចមិនរៀបរយរបស់ប្រជាជាតិអាស៊ីអាគ្នេយ៍ នៅខេត្តសៀមរាប ។

	- បានអញ្ជើញចុះតាមដាន និងត្រួតពិនិត្យគោលនយោបាយភូមិឃុំមានសុវត្ថិភាព នៅខេត្តកំពង់ឆ្នាំង ។ - បានអញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល និងប្រគល់ថវិកាជូនជនរងគ្រោះចំនួន ០៤នាក់ រួមនិងគ្រួសារដោយអំពើប្លន់តាមសមុទ្រនៅប្រទេសសូម៉ាលី ដែលរៀបចំឡើងដោយអង្គការការីតាសកម្ពុជា ។ - បានសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ចូលរួមធ្វើសម្ភាសន៍ជាមួយពលការិនីខ្មែរ ចំនួន ៨រូប ដែលបញ្ជូនត្រឡប់មកពីប្រទេសម៉ាឡេស៊ី ដោយមានជំនួយពីស្ថានទូត និងអង្គការ IOM ។ - រៀបចំមេរៀន និងកម្មវិធីសម្រាប់វគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីទទួលសេវាសមស្រប នៅតាមបណ្តាខេត្តចំនួន១០ រួមមាន ស្វាយរៀង ព្រៃវែង ក្រចេះ រតនគិរី កំពង់ស្ពឺ កំពង់ឆ្នាំង បាត់ដំបង ពោធិសាត់ ត្បូងឃ្មុំ និងមណ្ឌលគិរី ។ - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់របស់សង្គមស៊ីវិល ស្តីពីគោលនយោបាយទេសន្តរប្រវេសន៍កម្ពុជា-ថៃ "ការអនុវត្តល្អៗ បញ្ហាប្រឈម និងកាឡានុវត្តភាព" រៀបចំ ដោយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រីកម្ពុជា នៅសណ្ឋាគារសាន់រ៉ា រាជធានីភ្នំពេញ ។
ក្រសួងសង្គមកិច្ច	- បានចូលរួមក្នុងពិធីប្រគល់-ទទួលឯកសារផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការរយៈពេល០៣ឆ្នាំ សម្រាប់ការងារអនុវត្តច្បាប់ ស្តីពីយុត្តិធម៌អនីតិជន ។ - បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីយន្តការបណ្តឹងសម្រាប់ពលករទេសន្តរប្រវេសន៍ចំនួន០២ថ្ងៃ នៅសណ្ឋាគារ លី ហេងធាយ ក្រុងប៉ោយប៉ែត ដែលរៀបចំដោយអង្គការ MOI ។
ប៉ូលិស	- គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានសហការជាមួយ ក្រុមលេខាធិការដ្ឋានថ្នាក់ក្រុង បានធ្វើការប្រជុំប្រចាំខែឧសភា ដើម្បីផ្សព្វផ្សាយអំពីច្បាប់ ស្តីពីការបង្ការទប់ស្កាត់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់សមាជិកដែលមានចំនួន២៤នាក់(ស្រី១០នាក់)។
ខេត្តបាត់ដំបង	- ក្រុមការងាររលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរៀបចំខួបអនុស្សាវរីយ៍លើក១៣១ នៃទិវាពលកម្មអន្តរជាតិ ១ឧសភា ឆ្នាំ២០១៧ ក្រោមប្រធានបទ ដើម្បីសន្តិភាព ការងារ មុខរបរ និងអភិវឌ្ឍ ដែលមានអ្នកចូលរួមសរុប ២៦៨នាក់ (ស្រី១៧៨នាក់) នៅអ៊ីរ៉ូហ្ស ស៊ាមីតហ្ទូតវ៉ែ ស្រុកសំពៅលូន ។ - បានចូលរួមជាវ៉ាគ្មិនកិត្តិយសក្នុងកម្មវិធីសន្ទនាមតិពន្លឺមូលដ្ឋានរបស់វិទ្យុជាតិចំការចេក(FM 92.7 MHz) ខេត្តបាត់ដំបង ក្រោមប្រធានបទ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងឱកាសការងារនៅក្នុងប្រទេស នៅឃុំបឹងរ៉ាំង ស្រុកកំរៀង។

ខេត្តព្រះវិហារ	- ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយ ក្រុមការងារជំនាញបង្ការ-ទប់ស្កាត់ បានរៀបចំកិច្ចប្រជុំប្រចាំខែឧសភា ឆ្នាំ២០១៧ ដើម្បីរៀបចំគម្រោងផែនការអនុវត្តសកម្មភាពអំពីតួនាទី និងការកិច្ចដល់មន្ត្រីពាក់ព័ន្ធ ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់សិស្សានុសិស្ស ប្រជាពលរដ្ឋ បានចំនួន០៥ ក្រុង/ស្រុក មានសមាសចូលរួមមានចំនួន០៥ ស្រី០១នាក់ ។ - ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្តបានសហប្រតិបត្តិការជាមួយក្រុមការងារថ្នាក់ខេត្តប្រទេសវៀតណាម ដើម្បីរួមគ្នាការពារសន្តិសុខ ទប់ស្កាត់ប្រជាពលរដ្ឋធ្វើចំណាកស្រុកខុសច្បាប់ និងការជួញដូរមនុស្ស នៅតាមបណ្តោយព្រំដែននៃប្រទេសទាំងពីរ ។
ខេត្តឧត្តរមានជ័យ	- គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានសហការជាមួយ ក្រុមលេខាធិការដ្ឋាន បានរៀបចំកិច្ចប្រជុំប្រចាំខែឧសភា ឆ្នាំ២០១៧ ដើម្បីត្រួតពិនិត្យការគ្រប់គ្រងអនុវត្តអំពីតួនាទី និងការកិច្ចដល់មន្ត្រីពាក់ព័ន្ធភូមិ/ឃុំ/សង្កាត់/ក្រុង/ស្រុកការងារដឹកនាំ និងជំរុញឲ្យ ក្រុមការងារខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ដើម្បីគ្រប់គ្រងសភាពការណ៍បទល្មើស និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ បានចំនួន០៥ ក្រុង/ស្រុក មានសមាសចូលរួមមានចំនួន៣១៥ ស្រី៧៧នាក់ ។ - ក្រុមលេខាធិការដ្ឋាន គ ជ ខេត្ត.ប.ខ.បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការងារបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ដល់មន្ត្រីពាក់ព័ន្ធនៅក្នុងខេត្ត បានចំនួន០១វគ្គ មានសិក្ខាកាមចំនួន៤៤នាក់ ស្រី)៣៨នាក់។(
ខេត្តសៀមរាប	- ក្រុមការងាររលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត សម្របសម្រួលរបស់ក្រុមការងារទេសន្តរប្រវេសន៍ ក្រុមការងារអនុវត្តន៍ច្បាប់ ចូលរួមជាវាគ្មិន ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស នៅឃុំស្លែងស្ពាន ស្រុកស្រីស្នំ ដែលមានអ្នកចូលរួមសរុបចំនួន១៥០នាក់ (ស្រី៤៧នាក់)។ - មន្ទីរព័ត៌មានខេត្ត សហការជាមួយអង្គភាពជុំវិញខេត្ត អាជ្ញាធរ ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក និងអង្គភាពពាក់ព័ន្ធ ចូលរួមជាវាគ្មិន ដើម្បីផលិតកម្មវិធីសន្ធនាមតិ និងផ្សព្វផ្សាយច្បាប់ អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកមិនស្របច្បាប់ ជាពិសេសការស្វែងរកជំនួយពីអាជ្ញាធរ និងសង្គមស៊ីវិលនៅក្នុងខេត្ត ០៤ប្រធានបទ ។ - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមប្រជុំពិភាក្សាធ្វើផែនការ៣ឆ្នាំ ស្តីពីការអនុវត្តច្បាប់អនីតិជន នៅរាជធានីភ្នំពេញ មានអ្នកចូលរួមចំនួន១០០នាក់(ស្រី៤២នាក់)។ - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីជំនាញស៊ើបអង្កេត រៀបចំដោយអង្គការ AAPTIP នៅសណ្ឋាគារគ្រីបផាលែសភ្នំពេញ ។
ខេត្តកំពង់ធំ	- ក្រុមការងាររលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមសិក្ខាសាលាដើម្បីពិភាក្សា ស្តីពីប្រសិទ្ធភាពនៃការប្រើប្រាស់ជំនាញស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស នៅសណ្ឋាគារ ហ្ស្ត្រីនផាឡេស រាជធានីភ្នំពេញ ។ - ក្រុមការងាររលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីរបាយការណ៍កំណត់ទីតាំងសម្រាប់ថែទាំកុមារ និងសមាហរណកម្មកុមារពីមណ្ឌលចំនួន៣០% ទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាព នៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ។

ខេត្តកំពង់ចាម	- នាយរងការិយាល័យទទួលបន្ទុកប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ ក្រោមប្រធានបទផ្សព្វផ្សាយ និងការទប់ស្កាត់ការធ្វើអាជីវកម្មផ្លូវភេទ ដែលជ្រកក្រោមស្លាកខាវ៉ាអូខេ និងហាងម៉ាស្សា នៅមន្ទីរព័ត៌មានខេត្ត ។
ខេត្តបន្ទាយមានជ័យ	- ស្នងការដ្ឋាននគរបាលខេត្ត បានចាត់បញ្ជូនមន្ត្រីការិយាល័យជំនាញចំនួន០៣រូប ប្រចាំការនៅច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីសម្គាសពលករដែលអាជ្ញាធរថៃបញ្ជូនមក និងស្រាវជ្រាវរកមុខសញ្ញាពាក់ព័ន្ធអំពើជួញដូរមនុស្ស ។ - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមនៅគណៈកម្មាធិការ គ.ខ.ប.ជ ថ្នាក់ខេត្ត និងការយល់ដឹងអំពីអំពើជួញដូរមនុស្ស បានចំនួន០១លើក ។ - បានចូលរួមប្រជុំបូកសរុបលទ្ធផលការងារត្រីមាសទី១ និងផ្សព្វផ្សាយទិសដៅបន្តការងារក្នុងឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងអគ្គស្នងការដ្ឋាននគរបាលជាតិ ។
ខេត្តព្រះសីហនុ	- ក្រុមការងាររលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយក្រុមការងារជំនាញអន្តរមន្ទីរ បើកកិច្ចប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០១៧ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួម៤៦នាក់ ស្រី១៦នាក់ ។
ខេត្តកំពត	- គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានសហការជាមួយ ក្រុមលេខាធិការដ្ឋាន និងក្រុមការងារទាំង៦ បានធ្វើកិច្ចប្រជុំប្រចាំត្រីមាស និងឆមាស ដើម្បីត្រួតពិនិត្យការគ្រប់គ្រងអនុវត្តការងារដឹកនាំ និងជំរុញឲ្យ ក្រុមការងារខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ដើម្បីគ្រប់គ្រងសភាពការណ៍បទល្មើស និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ នៅក្នុងខេត្តទាំងមូល ។
ព្រៃវែង	- គណៈកម្មាធិការពិគ្រោះយោបល់ លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងស្នងការដ្ឋាននគរបាលខេត្ត បានធ្វើការប្រជុំប្រចាំខែ ដើម្បីផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងជំនាញប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់គណៈអភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ឲ្យពួកគាត់ជួយផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួនតាមរយៈ ពិធីមង្គលការ ពិធីបុណ្យ និងពិធីកម្សាន្តផ្សេងៗ ។
ស្វាយរៀង	- ស្នងការដ្ឋាននគរបាលខេត្ត បានចាត់បញ្ជូនមន្ត្រីការិយាល័យជំនាញចំនួន០១រូប ទៅចូលរួមសិក្ខាសាលា ស្តីពីការផ្សព្វផ្សាយក្រុមប្រតិបត្តិយេនឌ័រក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានសិក្ខាកាមចូលរួមចំនួន៦៤នាក់(ស្រី០៤នាក់) នៅសណ្ឋាគារកុ្ន\ពេញ រាជធានីភ្នំពេញ ឧបត្ថម្ភដោយអង្គការ AATIP ។
ខេត្តកណ្ដាល	- ក្រុមការងាររលេខាធិការដ្ឋានថ្នាក់ស្រុក បានបើកកិច្ចប្រជុំប្រចាំខែ ឆ្នាំ២០១៧ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានអ្នកចូលរួម៤៥នាក់ ស្រី២៥នាក់(០៣លើក)។